ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការដឹកនាំ
ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
លេខាធិការដ្ឋានអចិន្ត្រៃយ៍

# ឯកសារជំនួយស្មារតីស្តីពីវឌ្ឍនភាពការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលកម្ពុជា

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ គឺការសម្រេចឱ្យបាននូវប្រព័ន្ធច្បាប់និងប្រព័ន្ធយុត្តិធម៌មួយ ដែលអាចជឿទុកចិត្តបាននិងមានស្ថិរភាពសម្រាប់ការលើកស្ទួយការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូរបស់មនុស្ស, ការពង្រឹងគោលការណ៍នីតិរដ្ឋនៅក្នុងលិទ្ធិប្រជាធិបតេយ្យសេរី, ការធានាយុត្តិធម៌សង្គម ព្រមទាំងការបង្កើតបរិយាកាសជឿទុកចិត្តសម្រាប់ទាក់ទាញការវិនិយោគ។ ឆ្លើយតបទៅនឹងចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានសម្រេចនូវសមិទ្ធិផលធំៗជាច្រើនពាក់ព័ន្ធទៅនឹង ១. ការធ្វើទំនើបកម្មក្របខណ្ឌច្បាប់ ២. ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ ដល់មន្ត្រីអនុវត្តច្បាប់ ៣. ការកែលម្អប្រព័ន្ធតុលាការ និងការផ្តល់មធ្យោបាយបន្ថែមដល់ស្ថាប័នតុលាការ ៤. ការពង្រីកយន្តការដោះស្រាយវិវាទក្រៅប្រពន្ធ័តុលាការ និងកម្មវិធីជំនួយផ្នែកច្បាប់ ដែលមានខ្លឹមសារដូចខាងក្រោម៖

## ១. ការធ្វើទំនើបកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធវិស័យុត្តិធម៌

ក្នុងរយៈកាលកន្លងទៅ តុលាការកម្ពុជាបានអនុវត្តច្បាប់មួយចំនួនដែលបានបន្សល់ទុកពីសម័យរដ្ឋកម្ពុជាដែលមានដូចជា៖ ច្បាប់ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តក្នុងសម័យកាលអន្តរកាល ហៅកាត់ថា UNTAC ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ។

ប៉ុន្តែនាពេលបច្ចុប្បន្ននេះ ច្បាប់សំខាន់ៗជាច្រើនទាំងច្បាប់សារធាតុនិងច្បាប់នីតិវិធី ត្រូវបានអនុម័តនិងប្រកាសឱ្យប្រើសម្រាប់អនុវត្តនៅក្នុងប្រព័ន្ធតុលាការកម្ពុជា និងតាមការចាំបាច់នៃការគ្រប់គ្រងរដ្ឋ ដែលមានដូចខាងក្រោម៖

-ក្រមទាំង០៤ដែលជាច្បាប់គ្រឹះនិងមិនអាចខ្វះបានសម្រាប់វិស័យតុលាការរួមមាន ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ ក្នុងគោលដៅកែលម្អនិងបង្កើនប្រសិទ្ធភាពប្រព័ន្ធតុលាការ រាជរដ្ឋាភិបាលក៏បានរៀបចំតាក់តែង និងដាក់ឱ្យអនុវត្តនូវច្បាប់មូលដ្ឋានទាំងបីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ ដែលព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ នាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ដែលរួមមានច្បាប់ស្តីពី "ការរៀបចំអង្គការតុលាការ" ច្បាប់ស្តីពី "លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា" និងច្បាប់ស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម"

## ២. ការអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់

ក្នុងបេសកកម្មអប់រំ បណ្តុះបណ្តាលនិងផ្សព្វផ្សាយច្បាប់ ក្រសួងយុត្តិធម៌បានបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយច្បាប់ជាតិនិងអន្តរជាតិ ដល់មន្ត្រីអនុវត្តច្បាប់នៅតាមបណ្តាខេត្ត-រាជធានី ដែលជាចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ លើប្រធានបទជាច្រើនពាក់ព័ន្ធទៅនឹង ក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ ការអនុវត្តនីតិវិធីព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការចុះបញ្ជី ការគ្រប់គ្រងសំណុំរឿងក្តី និងរដ្ឋបាលតុលាការជាដើម ។

តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គការ JICA ដែលបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៩៩ ក្រសួងយុត្តិធម៌កំពុងតែអនុវត្តបញ្ចប់គម្រោងដំណាក់កាលទី៤ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៧ និងកំពុងបន្តដំណាក់កាលទី៥ ដើម្បីបង្កើនការយល់ដឹងអំពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ទៅដល់មន្ត្រីក្រសួងយុត្តិធម៌ តុលាការ អ្នកជំនាញច្បាប់ និងគ្រូបង្រៀននៅតាមសកលវិទ្យាល័យ និងដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ ។ សកម្មភាពគម្រោងដំណាក់កាលទី៥នេះ ត្រូវបានអនុវត្តតាមរយៈ ការអភិវឌ្ឍសមត្ថភាពនៃជនបង្គោលនៅតាមស្ថាប័នដែលពាក់ព័ន្ធ ការធ្វើទស្សនកិច្ចសិក្សានិងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងកម្ពុជានិងជប៉ុន និងការពង្រឹងការអនុវត្តច្បាប់តាមរយៈការផ្សព្វផ្សាយ ការតាក់តែងកំណត់ពន្យល់ និងលិខិតបទដ្ឋានផ្សេងៗពាក់ពន្ធ័ក្រមទាំងពីរនេះ។

តាមរយៈកិច្ចសហការជាមួយអង្គការអាឡឺម៉ង់ ខុនរ៉ាដអាដឺណោអ៊ែរនៅកម្ពុជា ក្រសួងយុត្តិធម៌បានធ្វើការសិក្សាស្រាវជ្រាវនិងរៀបចំតាក់តែងសៀវភៅជំនួយស្មារតីស្តីពី "ដំណើរការនិងរបៀបនៃ

ការតាក់តែងច្បាប់" និងបានធ្វើការផ្សព្វផ្សាយដល់អង្គភាពនីតិកម្ម នៅតាមក្រសួងស្ថាប័នផ្សេងៗ របស់រដ្ឋាភិបាល។

ក្រៅពីនេះ ក្រសួងយុត្តិធម៌ក៏បានធ្វើការផ្សព្វផ្សាយផងដែរតាមវិទ្យុនិងទូរទស្សន៍ នូវស្ប៉តអប់រំអំពីច្បាប់លើប្រធានបទផ្សេងៗពាក់ព័ន្ធនឹងក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណី និងការរៀបចំនិងដាក់ឱ្យដំណើរការអង្គភាពរដ្ឋបាលតុលាការ ជាដើម។

## ៣. ការកែលម្អនិងបង្កើនប្រសិទ្ធភាពប្រព័ន្ធតុលាការ

ក្នុងគោលដៅកែលម្អនិងបង្កើនប្រសិទ្ធភាពប្រព័ន្ធតុលាការ ក្រសួងយុត្តិធម៌ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើវិស័យយុត្តិធម៌ បានធ្វើការងារជាច្រើនតាមរយៈការកសាងក្របខ័ណ្ឌច្បាប់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងការគ្រប់គ្រងវិស័យយុត្តិធម៌ ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ការបង្កើនថវិការ និងការផ្តល់មធ្យោបាយបន្ថែមដល់ស្ថាប័នតុលាការ។ល។

ការរៀបចំនិងដាក់ឱ្យអនុវត្តច្បាប់គោលទាំងបីពាក់ព័ន្ធវិស័យយុត្តិធម៌កាលពីចុងឆ្នាំ២០១៤កន្លងទៅនេះ គឺក្នុងគោលដៅលើកដំកើនប្រសិទ្ធិភាពប្រព័ន្ធយុត្តិធម៌ ធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាយុតិធម៌ និងធានាបាននូវឯករាជ្យភាពនៃអំណាចតុលាការ តាមរយៈយន្តការដូចខាងក្រោម៖

-ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានបង្កើតឱ្យមានអង្គភាពរដ្ឋបាលតុលាការនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីជួយដល់តុលាការលើការងាររដ្ឋបាល ហិរញ្ញវត្ថុ ផែនការ និងការគ្រប់គ្រងសំណុំរឿងក្តី។ ច្បាប់នេះក៏នឹងបង្កើតឱ្យមានតុលាការជំនាញមាន ព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម និងការងារ ព្រមទាំងសាលាឧទ្ធរណ៍តំបន់ ដើម្បីដោះស្រាយបញ្ហាកកស្ទះសំណុំនៅតាមតុលាការ និងបង្វិតសេវាយុត្តិធម៌ឱ្យកាន់តែជិតប្រជាពលរដ្ឋ ។

-ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា បានកំណត់ច្បាស់លាស់នូវលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ដែលកម្ពុជាមិនធ្លាប់មានពីមុនមកនោះទេ ព្រមទាំងគោលការណ៏សំខាន់ៗមួយចំនួនទៀតក្នុងគោលដៅធានានូវឯករាជភាពនៃអំណាចតុលាការ ដូចជាការកំណត់ពីក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ និងមុខតំណែង កាកំណត់ពីសិទ្ធិ កតព្វកិច្ចនិងការទទួលខុសត្រូវ ការកំណត់ពីការជ្រើសរើស តែងតាំង ផ្លាស់ប្តូរនិងចូលនិវត្តន៍ ព្រមទាំងកាកំណត់ពីប្រាក់បៀវត្ស ប្រាក់ឧបត្ថមផ្សេងៗ ការការពារនិងទណ្ឌកម្មវិន័យជាដើម ។ល។

-ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានរៀបចំឡើងក្នុងគោលដៅជួយដល់ព្រះមហាក្សត្រក្នុងការធានាបាននូវឯករាជ្យភាពនៃអំណាចតុលាការ ដោយផ្អែកលើគោលការណ៍ពីរជាសំខាន់៖ ១. គោលការណ៍នៃភាពជាតំណាង ទាំងភាពជាតំណាងតាមការបោះឆ្នោត និងភាពជាតំណាងចេញពីស្ថាប័ននានា។ ភាពជាតំណាងនេះចេញមកពី អំណាចនីតិប្បញ្ញត្តិ រួមមានព្រឹទ្ធសភានិងរដ្ឋសភា ភាពជាតំណាងនៃអង្គចៅក្រម រួមមានសាលជម្រះក្តីជាន់ខ្ពស់ សាលជម្រះក្តីជាន់ទាប អង្គការអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និងអង្គការអយ្យការអមសាលាជម្រះក្តីជាន់ទាប ភាពជាតំណាងនៃអំណាចនីតិប្រតិបត្តិគឺរដ្ឋមន្រ្តីក្រសួងយុត្តិធម៌ និងភាពជាតំណាងពីស្ថាប័នកំពូលជាតិនិងឯករាជ្យមួយទៀតគឺក្រុមប្រឹក្សាធម្មនុញ្ញ។ ២. គោលការណ៍តុល្យភាពនៃអំណាច គឺធានាតុល្យភាពនៃអំណាចទាំងបី រួមមានអំណាចនីតិប្បញ្ញត្តិ, អំណាចតុលាការ និងអំណាចនីតិប្រតិបត្តិ ដែលត្រូវមានតំណាងចូលរួមក្នុងសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បើទោះបីជាសមាជិកភាគច្រើនជាចៅក្រម និងព្រះរាជអាជ្ញាក៏ដោយ។

ទន្ទឹមនឹងនេះ ដើម្បីផលិតបន្ថែមនូវធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ប្រកបដោយសមត្ថភាព និងវិជ្ជាជីវៈ នៅឆ្នាំ២០០២ រាជរដ្ឋាភិបាលបានបង្កើតសាលាភូមិន្ទចៅក្រម ហើយនៅឆ្នាំ២០០៨ បង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដែលបច្ចុប្បន្នមានសាលាវិជ្ជាជីវៈចំនួន០៥គឺ សាលភូមិន្ទចៅក្រម សាលាភូមិន្ទក្រឡាបញ្ជី សាលាភូមិន្ទសាការី សាលាភូមិន្ទអាជ្ញាសាលា និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

ចំនួនចៅក្រមនិងព្រះរាជអាជ្ញានាពេលបច្ចុប្បន្ន បានកើនឡើងរហូតដល់ប្រមាណជិត ៦០០រូប ដែលកាលពីឆ្នាំ១៩៩៣មានប្រមាណជា១០០រូប ឆ្នាំ២០០៣មានប្រមាណជិត២០០រូប និងឆ្នាំ២០១៣មានប្រមាណជា៤០០រូបតែប៉ុណ្ណោះ។ ចំណែកឯការជ្រើសរើស និងបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាតាមរយៈរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាកាក៏បានរៀបចំឡើងបានចំនួន៨ជំនាន់រួចមកហើយដែរដែលមានចំនួនសរុប ៤៥៤រូប ដែលក្នុងនោះមួយជំនាន់មាន ៥៥រូប និងលើកលែងតែជំនាន់ទី៣ និងទី៤តែប៉ុណ្ណោះ ដែលមួយជំនាន់មាន ៦២រូប។

ចំណែកឯក្រឡាបញ្ជីនាពេលបច្ចុប្បន្នមានចំនួនសរុបប្រមាណជា៨០០រូប ហើយការជ្រើសរើសនិងបណ្តុះបណ្តាលក្រឡាបញ្ជីនៅរាជបណ្ឌិតសភាវិជ្ជាវៈតុលាការបានរៀបចំឡើងបាន៤ជំនាន់ និងមានចំនួនសរុប ៣៨១រូប។ ការជ្រើសរើសនិងបណ្តុះបណ្តាលសិស្សអាជ្ញាសាលា និងសារការី នៅរាជបណ្ឌិត

សភាវិជ្ជាជីវៈតុលាការ គឺបានតែមួយជំនាន់ទេ ដែលក្នុងនោះ សិស្សអាជ្ញាសាលាមានចំនួន ២៨រូប និង សារការីមានចំនួន ១៥រូប បានទទួលនូវការបណ្តុះបណ្តាលរួច។

ចំពោះការជ្រើសរើសនិងការបណ្តុះបណ្តាលមេធាវី នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី មកដល់បច្ចុប្បន្នគឺបានរៀបចំចំនួន១៥ជំនាន់រួចមកហើយ ដែលមានសិស្សមេធាវីទទួលការបណ្តុះបណ្តាល រួចមានចំនួនសរុប ៧៧២រូប។ ចំណែកឯមេធាវីពេញសិទ្ធិដែលកំពុងប្រកបវិជ្ជាជីវៈមានចំនួន ១,០៨៩រូប គឺមានការកើនឡើងច្រើនបើធៀបទៅនឹងឆ្នាំ២០០៣ ដែលពេលនោះមេធាវីមានចំនួនប្រមាណតែ ៣៥០ រូបប៉ុណ្ណោះនៅទូទាំងប្រទេស។

ក្នុងគោលដៅកែលម្អនិងបង្កើនប្រសិទ្ធភាពស្ថាប័នតុលាការ និងបន្ថែមលើយន្តការនៃការកសាង ក្របខ័ណ្ឌច្បាប់ និងការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យយុត្តិធម៌ រាជរដ្ឋាភិបាលក៏បានបង្កើន ថវិការជាតិសម្រាប់វិស័យយុត្តិធម៌ និងផ្តល់មធ្យោបាយបន្ថែមផងដែរដល់ដល់ស្ថាប័នតុលាការ ជាក់ស្តែង នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលទើបតែដំឡើងប្រាក់បំណាច់មុខងារជូនដល់ចៅក្រមនិងព្រះរាជអាជ្ញា តាម រយៈអនុក្រឹត្យចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ នេះ ដើម្បីជាការលើកទឹកចិត្ត និងធានាបាននូវប្រសិទ្ធភាព ការងាររបស់ចៅក្រម និងព្រះរាជអាជ្ញា។ ថវិការជាតិ សម្រាប់វិស័យយុត្តិធម៌ ក៏មានការកើនឡើងជាលំដាប់ដែរ ដោយឆ្នាំ២០០៣ មានចំនួនសរុប ៩៦៥០លាន រៀល ឆ្នាំ២០០៨មានចំនួន ២២៦៦០លានរៀល ឆ្នាំ២០១៣មានចំនួន ៥០៩៦៣លានរៀល ឆ្នាំ២០១៤មានចំនួន ៥៥០៣១លានរៀល ឆ្នាំ២០១៥ មានចំនួន ៦៦៦៣១លានរៀល ឆ្នាំ២០១៦មានចំនួន ៩៤២៣៩លានរៀល ឆ្នាំ២០១៧ មានចំនួន ១១៦៧៥០លានរៀល និងឆ្នាំ២០១៨ កើនឡើងដល់ ១៣៨៣២១លានរៀល។

### ៤. ការងារផ្តល់ជំនួយផ្នែកច្បាប់ និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ក្នុងការអនុវត្តការងារផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ក្រសួងយុត្តិធម៌បានធ្វើការសហការ យ៉ាងជិតស្និត ជាមួយគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា ក្នុងការរៀបចំមេធាវីសម្រាប់ការពារក្តី ដល់ជនក្រីក្រ ទៅតាមសំណើរបស់ តុលាការ និងសមីខ្លួន។ ក្នុងចំណោមមេធាវីពេញសិទ្ធិ និងកំពុង ប្រកបវិជ្ជាជីវៈទាំង១,០៨៩រូប នាពេលបច្ចុប្បន្ន មានមេធាវីស្ម័គ្រចិត្តការពារក្តីជូនជនក្រីក្រចំនួន ៤១៥រូប ហើយថវិការជំនួយផ្នែកច្បាប់សម្រាប់ជនក្រីក្រនេះ ត្រូវបានរដ្ឋាភិបាលបង្កើនឡើងចំនួនសរុប ៩០០ លានរៀល សម្រាប់ឆ្នាំ២០១៨នេះ ។ មេធាវីស្ម័គ្រចិត្តរបស់គណៈមេធាវី បានធ្វើការការពារក្តីជូនជន

ក្រីក្រនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ មានចំនួនជាមធ្យម ២០០០ករណី ក្នុងមួយឆ្នាំ ចំណែកឯការផ្តល់សេវាពិគ្រោះផ្នែកច្បាប់ដល់ជនក្រីក្រ មានចំនួនជាមធ្យម ៣០០ករណី ក្នុងមួយឆ្នាំ ។

ក្រសួងយុត្តិធម៌ ក៏បានបង្កើតនូវយន្តការផ្តល់ព្រឹក្សាពិគ្រោះយោបល់ផ្នែកច្បាប់ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផងដែរ ជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាននិងសហគម ដោយយកចិត្តទុកដាក់ តាមរយៈការបង្កើតឱ្យមានមណ្ឌលសេវាយុត្តិធម៌ថ្នាក់ស្រុក ក្រុង ខណ្ឌ ទាំង៤០ នៅទូទាំង ១០ រាជធានី-ខេត្ត ដែលមាន ៨ក្រុង ២០ស្រុក និង១២ខណ្ឌ ហើយដែលបានផ្តល់ប្រឹក្សាផ្នែកច្បាប់ និងដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅមូលដ្ឋាន បានចំនួនជាមធ្យម ១០០០ករណី ក្នុងមួយឆ្នាំ។

## ៥. សេចក្តីសន្និដ្ឋាន

ក្នុងការងារអនុវត្តនូវភារកិច្ចនិងការងាររហូតសម្រេចបាននូវលទ្ធផល ដូចបានរៀបរាប់ជូនខាងលើនេះ ក្រសួងបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជាធនធានមនុស្ស ធនធានហិរញ្ញវត្ថុ សម្ភារៈបរិក្ខា និងសំណង់អាគារសម្រាប់ធ្វើការជាដើម ដែលមិនទាន់ឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងតម្រូវការ និងទំហំការងាររបស់ក្រសួងនាពេលបច្ចុប្បន្ន ជាពិសេសទំហំការងារ តួនាទីនិងភារកិច្ច ការទទួលខុសត្រូវរបស់ក្រសួងដែលតម្រូវដោយច្បាប់មូលដ្ឋានទាំងបី ដែលតម្រូវឱ្យក្រសួងត្រូវមានថវិកាច្រើនជាងមុន ចំនួនបុគ្គលិកដែលពោរពេញដោយជំនាញនិងសមត្ថភាពច្រើនជាងមុន ព្រមទាំងសម្ភារៈបរិក្ខា សំណង់អាគារសម្រាប់មន្ត្រីធ្វើការច្រើននិងមានទំហំធំជាងមុនផងដែរ ។ សម្រាប់ទិសដៅការងារបន្ត ក្រសួងនឹងបន្តអនុវត្តនូវភារកិច្ចសំខាន់ៗនៃការងារកំណែទម្រង់ច្បាប់និង ប្រព័ន្ធយុត្តិធម៌ មានដូចខាងក្រោម ៖

-បន្តអនុវត្តនូវច្បាប់មូលដ្ឋានទាំងបីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ ដូចជាការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តិមួយចំនួនទៀតដែលតម្រូវដោយច្បាប់ទាំងបី រៀបចំដាក់ឱ្យដំណើរការរដ្ឋបាលតុលាការនៅតាមតុលាការគ្រប់ជាន់ថ្នាក់ រៀបចំដាក់ឱ្យដំណើការតុលាការជំនាញ និងសិក្សារៀបចំបង្កើតឱ្យមានសាលាឧទ្ធរណ៍តំបន់....។ល។

-ក្រសួងនឹងនៅតែបន្តរៀបចំតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ និងសិក្សាធ្វើវិសោធនកម្មលិខិតបទដ្ឋានមួយចំនួនទៀងដែលកំពុងតែអនុវត្ត ដើម្បីឱ្យឆ្លើយតបបានទៅនឹងស្ថានភាពជាក់ស្តែងរបស់កម្ពុជានាពេលបច្ចុប្បន្ន។

-បន្តការងារអប់រំ បណ្តុះបណ្តាលនិងផ្សព្វផ្សាយច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ ឱ្យមានសមត្ថភាព និងការទទួលខុសត្រូវវិជ្ជាជីវៈខ្ពស់ជាងមុន ។

-បន្តពង្រឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ កម្មវិធីជំនួយផ្នែកច្បាប់ ការងារអធិការកិច្ចតាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ នៅតាមសាលាជម្រះក្តី គ្រប់ជាន់ថ្នាក់ ព្រមទាំងពង្រឹងកិច្ចសហការអនុវត្តច្បាប់ជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ ដោយផ្តល់នូវការគាំទ្រផ្នែកជំនាញបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារៈបរិក្ខាដល់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីឱ្យការអនុវត្តការងារ និងភារកិច្ចរបស់ខ្លួន ទទួលបានប្រសិទ្ធភាពខ្ពស់ ។

-បន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឱ្យទទួលបានជោគជ័យ។